ត្រូវប្រាកដប្រជាជាផ្ទះរបស់អ្នកគ្មានថ្នាំលាប ដែលមានជាតិសំណ

ថ្នាំលាបមានជាតិសំណ អាចធ្វើឲ្យកូនក្មេងឈឺយ៉ាងធ្ងន់ណាស់ ។

ការពុលនឹងថ្នាំលាបមានជាតិសំណ អាចបណ្តាលឲ្យខូចខួរក្បាល។

ថ្នាំលាបមានជាតិសំណគេបានរកឃើញនៅក្នុងផ្ទះចាស់ៗ ។ វាអាចជាមាននៅខាងក្នុង និងនៅខាងក្រៅផ្ទះ ។

បើសិនជាអ្នកគិតថា អ្នកប្រ-ហែលជាបាននៅជិតថ្នាំលាបមានជាតិសំណ នោះត្រូវពិ-សោធមើលឈាមកូនរបស់អ្នក ។ ចូរនិយាយទៅកាន់គ្រូពេទ្យរបស់អ្នក ឬប្រាប់មន្ទីរពិនិត្យរោគារបស់អ្នក ។

សំណក៏អាចបានរកឃើញនៅក្នុងគ្រឿងលំអសម្ផស្ស និងក្រឡផ្ងរដែរ ។ បើសិនជាអ្នកគិតថាកូនរបស់អ្នកប្រហែលជាបាននៅជិតជាតិសំណ នោះត្រូវយកកូនទៅមន្ទីរពិនិត្យរោគា ដើម្បីពិសោធមើលឈាមយ៉ាងពិសេស ។

FIRST 5 CALIFORNIA

ល្បិចក្តីសុខសាន្ត នៃការពុលនឹងជាតិសំណ

សេចក្តីគ្រោះថ្នាក់ នៃការពុលនឹងជាតិសំណ

ល្បិចដើម្បីធ្វើឲ្យប្រាកដ ថាក្មេងត្រូវបានការពារពីការគ្រោះថ្នាក់នឹងជាតិសំណ

ស្នើគ្រូពេទ្យរបស់អ្នក ឬអ្នកធ្វើការខាងសុខភាព ឲ្យគេពិសោធរកមើលជាតិសំណសំរាប់កូនរបស់អ្នក នៅអាយុ 1 ឆ្នាំ ។

កូនក្មេងភាគច្រើនដែលមានការពុលនឹងសំណ មើលទៅដូចជាគ្មានឈឺអ្វី ឬមានកិរិយាជាឈឺឡើយ ។

ការពិសោធន៍នឹងប្រាប់គ្រូពេទ្យ ឲ្យដឹងថាតើកូនរបស់អ្នកមានជំងឺឬអត់ ។

ការពិសោធន៍ ការពុលជាតិសំណគឺឥតអស់ប្រាក់កាសអ្វីទេ បើសិនជាកូនរបស់អ្នកមាន Medi-Cal ឬនៅក្នុងសុខភាពកុមារ និងកម្មវិធីបង្ការភាពពិការ (Child Health and Disability Prevention Program-CHDP) ។ ក្រុមហ៊ុនធានារ៉ាប់រងជាច្រើន ក៏នឹងចេញថ្លៃសំរាប់ការពិសោធន៍នេះដែរ ។

តើចង់ដឹងថែមទៀត អំពីការពុលនឹងជាតិសំណ ដែរឬទេ?

ទូរស័ព្ទទៅលេខប្រចាំការពុលសំណ :
(800) 532-3394

ការការពារកូនក្មេងពីការពុលនឹងជាតិសំណ

©2003 First 5 California